# ការសម្ភាសន៍របស់លោកយាយ តួន យ៉ុន

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិន្ទ    ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ តួន យ៉ុន**

## ពត៌មានសង្ខេបរបស់លោកយាយ តួន យ៉ុន

សព្វថ្ងៃនេះលោកយាយតួន យ៉ុនមានអាយុ៦៨ឆ្នាំហើយ គាត់មានបងប្អូនចំនួន៦នាក់ តែនៅរស់រាន មានជីវិតតែ៣នាក់ទេ គាត់ជាកូនទី៥ក្នុងគ្រួសារ។ កាលពីកុមារភាពជីវិតរបស់គាត់មានភាពរីកយាយ និងសុខស្រួល តែពេលចូលដល់សម័យប៉ុល ពតមកដល់គាត់ត្រូវបាត់ឪពុក និងបងប្អូនអស់ចំនួន៣ នាក់ដោយសារតែប៉ុល ពតយកទៅសម្លាប់ចោល។ គាត់ខិតខំតស៊ូក្នុងការធ្វើការងារក្នុងកងនារីជារៀង រាល់ថ្ងៃ ហើយគាត់តែតែត្រូវបានមនុស្សជុំវិញខ្លួនឲ្យរួចពីគ្រោះថ្នាក់ម្តង។ បន្ទាប់ពីប៉ុល ពតហើយគាត់ក៏ ត្រលប់មកនៅស្រុកកំណើតរបស់គាត់វិញ ហើយមានក្រុមគ្រួសារតែជីវិតរបស់គាត់ជួបទុក្ខលំបាក ដោយសារតែមានជីវភាពក្រីក្រពេក។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់យាយដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់យាយ ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រី ហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់ សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយ របស់យាយអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាយាយ។ បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍យាយចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់យាយណឹង នៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodiaoralhistory.byu.edu ណា យាយ ចឹងតើយាយយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់យាយចូលទៅក្នុងវេបសាយរបស់ សាលាទេយាយ?

ខៈ ព្រម។

កៈ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍យាយនេះគឺ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ហើយ ការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្នៀស សង្កាត់ចុងឃ្នៀស ស្រុកសៀមរាប ខេត្ត

សៀមរាបណាយាយ ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិទ្ធ អញ្ចឹងខ្ញុំចង់សួរថាតើយាយមានឈ្មោះពេញឈ្មោះអ្វីដែរយាយ?

ខ៖ ឈ្មោះតួន យ៉ុន។

ក៖ ចុះអ្នកយាយមានឈ្មោះហៅក្រៅទេអ្នកយាយ?

ខ៖ តែមួយប៉ុណ្ណឹងឯង។

ក៖ ចុះយាយមានអាយុប៉ុន្មានហើយឆ្នាំណឹង?

ខ៖ អាយុ៦៨ឆ្នាំ។

ក៖ ចុះយាយចាំថ្ងៃខែឆ្នាំកំណើតយាយបានទេយាយ?

ខ៖ អត់ចាំទេចាំតែអាយុប៉ុណ្ណោះឯង។

ក៖ ចុះឆ្នាំខ្មែរយាយកើតឆ្នាំណាដែរ?

ខ៖ មិនបានចាំទាំងអស់ ព្រោះសព្វថ្ងៃចាស់ទៅវាភ្លេច។

ក៖ ចុះយាយមានស្រុកកំណើតនៅឯណាដែរយាយ?

ខ៖ ចុងឃ្មៀស ភ្នំក្រោម ចុងឃ្មៀសនេះឯង។

ក៖ នៅនេះតាំងពីតូចម៉ង?

ខ៖ នៅនេះតាំងពីតូច តាំងពីកើតមក។

ក៖ ចុះយាយមានបងប្អូនប៉ុន្មាននាក់ដែរយាយ?

ខ៖ បងប្អូននោះអាពតវាយកទៅវៃចោលអស់ហើយនៅសល់តែ៣នាក់ទេ។

ក៖ បាទបើសរុបទាំងអស់ ទាំងអ្នកស្លាប់អ្នករស់ប៉ុន្មាននាក?

ខ៖ សរុបទាំងអស់ស្លាប់វាមានចំនួន៦នាក់ ឆឹត ឆាប ឆុំ ឡៃ ខ្ញុំ អាវ៉ាន់ហេងពៅ។

ក៖ ចុះយាយជាកូនទីប៉ុន្មានដែរយាយ?

ខ៖ កូនបន្ទាប់ពៅ កូនទី៥។

ក៖ ចុះបងប្អូនយាយដែលនៅរស់៣នាក់ទៀតណឹងគាត់រស់នៅឯណាសព្វថ្ងៃ?

ខ៖ នៅនេះឯងទាំងអស់គ្នា។

ក៖ យាយធ្លាប់ធ្វើអ្វីខ្លះដែរជាមួយបងប្អូនកាលនៅក្មេងយាយអាចប្រាប់បានទេ?

ខ៖ ប្រាប់បានកាលនៅពីក្មេងជុំគ្នា ធ្វើចំការ ចំការសណ្តែកនៅណឹងជុំគ្នានេះឯងបណ្តោយ ធ្វើចំការសណ្តែកកាលណឹងនៅតូចៗណា នៅតូចទេវាចូលអាយុ១៦ឆ្នាំដល់ចូលដល់វ៉ៃដាច់ទៅវាចូល១៧ឆ្នាំ ១៧ឆ្នាំក៏គេឲ្យនៅរែកព្រួលរែកអីនៅនេះឯងណា រែកព្រួលទៅបានរយៈប្រហែលជា១ឆ្នាំគេបញ្ជូនទៅនៅឃ្លាំង ដល់នៅឃ្លាំងបានប្រហែលជា១ឆ្នាំគេជម្លៀសគេយកឪពុក និងបងប្អូនទៅគេថាយកទៅកសាងឲ្យទៅរៀនសូត្រ ការពិតនោះគេមិនយកទៅកសាងរៀនសូត្រទេគេយកទៅវ៉ៃចោល គេយកទៅវ៉ៃចោលមែនណាកូនរហូតដល់បែកគ្នាទាល់សព្វថ្ងៃ បងប្រុស៣នាក់ ២នាក់នោះគេយកទៅវ៉ៃចោលទៅ ១ទៀតយើងសិស្សសាលាគេថាយើងចេះដឹងគេយកយើងទៅវ៉ៃចោលដែរ គាត់ថ្នាក់ទី១ពីដើមណា  ប្រលងបាក់ឌុបហើយដល់ពេលនេះទៅខ្ញុំក៏ជម្លៀសយកបងប្អូនទៅអស់ក៏គេជម្លៀសម្តាយជម្លៀសខ្ញុំជីដូនចាស់ទៅនៅកំពង់ក្តី ទៅនៅកំពង់ក្តីយើងដើរទៅអត់មានជិះឡានទេគេឲ្យដើរ ដើរនោះជីដូនចាស់ដើរអត់រួចទេនាំគ្នាធ្វើស្នែងសែងតាមដុប ដើរតាមដុបព្រៃវត្តព្រែកប្រោសណា ទៅដល់វត្តព្រែកប្រោសភ្លៀងអើយភ្លៀង ភ្លៀងខ្លាំងណាស់ក្នួយរកទឹកដាំបាយគ្មានទេ យាយដាច់ចិត្តទៅសំពះសុំទឹកគេសុំទឹកពួកតំបន់ចាស់ណា ចុះទឹកគ្នាមានទឹកដែរបើគ្នាយើងមានរាប់ពាន់នាក់ទៅដងទឹកគ្នាមិនអស់ហើយចឹងហើយអ្នកណាឲ្យចូលក៏ចូលគេមិនឲ្យចូលក៏ហី មានតែយាយមួយទេដែលគេឲ្យទៅដងទឹកនៅវត្តព្រែកប្រោសសុំអណ្តូងគេព្រោះយាយទៅដល់លើកដៃសំពះគេសុំទឹកដាំបាយ ហេតុតែគុណបុណ្យលោកជួយទៅដល់បានទឹកមកហើយដើរដល់ពាក់កណ្តាលផ្លូវភ្លៀងធ្លាក់មកបានទឹកនោះឯងដាំបាយ ដល់ពេលព្រឹកឡើងទៀតគេជម្លៀសពីព្រែកប្រោសឡើងមកតាមថ្នល់ជាតិហើយ ឡើងមកថ្នល់ជាតិយើងទៅគេបញ្ជូនមកនៅកំពង់ក្តី អរមកនៅថ្នល់កែង គេជម្លៀសយើងមកនៅថ្នល់កែង ដល់មកដល់ថ្នល់កែង អរអត់ទាន់ដល់ថ្នល់កែងទេកូន អេថ្នល់កែងហើយដឹង ដល់ថ្នល់កែងគេឲ្យយើងកាប់ដីលើកប្រព័ន្ធភ្លឺស្រែណា ទៅនារីៗម្តាយអ៊ុំអត់មានអីស៊ីទេព្រឹកឡើងគេឲ្យបបរមួយវែក មួយវែកសរ ទៅក៏ម្តាយឡើងទៅបេះផ្លែនៃ ស្អីអាផ្លែកកោះ

យើងណា ផ្លែកកោះអីមិនមែនកកោះអានោះគ្រាប់កកោះ គេហៅផ្លែនៃត្រពុកម៉េចទេ ក្រឡោម ភ្លុកម៉េចទេ យកមកបន្ទុំ ទុកឲ្យកូនមួយថ្ងៃៗហូប ពេលចេញពីធ្វើការចេះយើងអត់មានអីហូបវា បបរមួយវែកលាយព្រលិត លាយដើមនៃអាដើមនេះៗរឹងៗយកមកដល់ហូប ដាក់មួយម៉ាត់ទៅ ក្នុងមាត់ហើយបានដាក់អំបិលចិតទៅ ចុកបបរមួយចុងស្លាព្រារកំសត់ណាស់ ចុកបបរមួយចុង ស្លាបព្រាណឹងឯងក៏ហូបដល់ម្ដាយនឹកឃើញអាណិត ទៅបេះអាដើមនោះផ្លែនោះឯងមកបន្ទុំ ទុកឲ្យកូនព្រឹកឡើងឲ្យមួយថ្ងៃមួយ ឲ្យប្អូនពៅនោះមួយ អាវ៉ាន់ហេងនោះមួយខ្ញុំមួយ ទៅក៏ គ្រាន់ហូបដល់តែពេលយូរៗទៅមិនបានរយៈប្រហែលជា១ខែគេជម្លៀសទៅដាក់និងវត្តវិហារ ព្រហ្ម គ្នាច្រើនណាស់រាប់រយរាប់ពាន់នាក់ ដល់ទៅដាក់វត្តវិហារព្រហ្មទៅគេឲ្យយើងលើក ទំនប់លើកភ្លឺធម្មតាធ្វើស្រែ ធ្វើស្រែនិងចប បើអ្នកណាគេអត់ធ្វើគេវ៉ៃចោល បើយើងដើរចេញដូរ ចេញអីគេចាប់បានគេវ៉ៃចោល ដល់យាយនេះនៅក្មេងវាមិនសូវជាដឹងអីប៉ុន្មានទេកាលនោះ ណា ទៅក៏កាប់ស្រែបណ្ដើររើសមើមក្លុង មើលក្លុងអាក្រហាមប៉ុនៗនេះដាក់ថ្នក់សំឡុយទុកហូប ដល់ពេលចូលមកកន្លែងវិញគេឲ្យបបរបានបេះនៃដើមថ្ងៃមានបោចមកក្រហមង៉ៅរឹងដូច អង្កត់ អុស ទៅលាងទឹកឲ្យស្អាតបានដាក់នៅថ្នក់សំឡុយយកមកគេបើកបបរឲ្យមួយចាន មួយចាន មួយវែកយើងណឹងណា ទៅគេដាក់អំបិលមួយចុងស្លាបព្រា ទៅក៏បេះអាស្លឹកអំពិលនៅក្រោម ដើមអំពិលបេះមកក៏ដាក់ក្នុងមាត់ទៅក៏បេះអាស្មៅនោះឯងយកមកចុកមាត់ ឲ្យពេញមាត់ទៅក៏ ដុសបបរមួយចុងស្លាបព្រាចុកដើម្បីឲ្យវាធូន់ក្រពះណា ទៅក៏ហូបរាល់ថ្ងៃ ដល់ពេលថ្ងៃនោះ ឯងនិយាយឲ្យអស់ចុះណា ថ្ងៃនោះឯងចង់សន្លប់ឃើញគេវ៉ៃកូនក្មេង ចាប់បោកនិងគល់ត្នោត អាយុប្រហែល៨ខែ ដែលគេថាម៉ែវាក្បត់ណាគេយកកូននោះឯងទៅ ទៅក៏វាចាប់លើកប្រលែ ងៗក៏ចាប់បោះទៅលើចាប់ជើងបោកនិងគល់ត្នោត អ៊ុំចង់សន្លប់ឃើញចឹងសន្លប់ងងឹតមុខដួល វាអាណិតក្មេងណា ដល់ងងឹតមុខដួលទៅពួកយោធានេះវាសួរ ថាម៉េចបានមិត្តឯងដួលមិត្តឯង តក់ស្លុតហា ទៅក៏អ៊ុំប្រាប់គេថាអ៊ុំអត់ស្រួលខ្លួនអត់ហ៊ានប្រាប់គេថាតក់ស្លុតទេខ្លាចគេយក យើងទៅវ៉ៃចោលទៀត ថាខ្ញុំងងឹតខ្ញុំវិលមុខខ្ញុំអត់ស្រួលខ្លួន អាបើមិនស្រួលខ្លួនងើបមកកាប់ដៃ ថែមទៀតទៅ ភ័យណាស់ខ្លាចគេយកយើងទៅវ៉ៃចោលថៅទាញចបបានកាប់ដីទៀត កាប់ដី ទៀតក៏នៃ មកផ្ទះវិញមកផ្ទះវិញក៏នៃយប់ឡើងគេឲ្យនៅយាម ផ្លាស់គ្នាឲ្យយាមនារីៗណា យាម ពួកដែលគេចាប់ដាក់ក្នុងគុកនោះ គុកនោះទៀតប៉ុននេះឯង ឲ្យអង្គុយគ្នាសុទ្ធតែអង្គុយអោន នៅអ្នកដើរដូរស៊ី ហើយអាខ្លះបានអង្ករទៅគេចាប់បានទៅគេវ៉ៃចោល ខ្លះបានបាយក្រៀមគេ ចាប់បានគេវ៉ៃចោលងាប់ច្រើនណាស់គេចាប់វ៉ៃចោលនៅវិហារព្រហ្មងាប់ច្រើនណាស់ ទៅក៏ ដូចនៃអ្នកណាដូចថាមិនហ៊ានដើរសុខចិត្តអត់ឃ្លាន សុខចិត្តទ្រាំអត់ នោះបានៗមកដល់ផ្ទះបា នៗមកដល់ ដល់រយៈប្រហែលជា១ខែដែលគេចាប់មនុស្សវ៉ៃចោលអ្នកខុសអីគេវ៉ៃចោលអស់

ទៅនៅ ប៉ុន្មាននាក់ប្រហែលជាចាស់ៗប្រហែលជា២០០នាក់ទាំងចាស់ទាំងក្មេងគេចាប់បំបែក ចាប់បំបែកកម្តាយ ម្តាយនោះទៅផ្សេងខ្ញុំទៅផ្សេង ប្អូនទៅផ្សេង ទៅក៏ខ្ញុំអាណិតប្អូននោះពេក គេបំបែកម្តាយទៅនៅស្អីល្វែងឬស្សីប្អូននោះនៅថ្នល់កែងបងនោះនៅកំពង់ក្តីនៅសាលាកំពង់ក្តីណា ទៅក៏ខ្ញុំនេះនៅនារីនេះ៣០០នាក់ នារី៣០០នាក់ ស្រាប់តែដល់ពេលយូរទៅវាយកទៅវៃចោលនៅសល់តែនារីចេញមកសល់៧០នាក់ទេ ហើយពួកយុវណ្ណ ប្រហែល២០០នាកនៅយុវណ្ណប៉ុន្មាន៦ ៧នាក់ ពេលយប់ឡើងចេះដែលល្ហើយខ្លាំងពេលនឹកម្តាយ ម្តាយនៅឆ្ងាយណាស់នឹក ឯល្វែងឬស្សីពីកំពង់ក្តីទៅល្វែងឬស្សីឆ្ងាយណាស់កូន យប់ឡើយលួចដើរទៅ ដើរគ្នា៣នាក់មានមីផាមួយ ខ្ញុំមួយ មីលួមមួយ ៣នាក់ដើរយប់ ម៉ោង១នាំគ្នាលួចចេញអត់ឲ្យគេដឹងទេ គេចាប់បានគេវៃចោលទៅក៏ដើរទៅរកម្តាយ អត់ដែលស្គាល់ទេមិនដឹងម្តាយនៅឯណាទេ ក៏ដើរទៅរកទៅហួសដល់ស្នោង អត់ស្គាល់ល្វែងឬស្សីហួសទៅដល់ស្នោង ទៅដល់សួរអ្នកស្រុកនោះហេតុតែគេចិត្តល្អដែរណាមានអ្នកចិត្តល្អខ្លះគេសួរថានាងនាងឯងទៅណា ថាខ្ញុំរកល្វែងឬស្សីម៉ែខ្ញុំគេជម្លៀសមកដាក់ល្វែងឬស្សីនេះឯង ទៅក៏ពួកអ្នកស្រុកនោះឯងគេថាអឺកូនចៅអ្នកទន្លេហា ខ្ញុំថាចាស កូនចៅអ្នកទន្លេល្អៗណាស់គេថាណាទៅសួរថាក្មួយអើយហួសហើយក្មួយឯងដើរតិចទៅ ក្មួយឯងហួសផុតតែពីស្ពាននេះទៅក្រោមវិញក្មួយឯងចូលទៅនោះឯងគេហៅថាល្វែងឬស្សី ទៅក៏ពួកខ្ញុំដើរចូលមកវិញក៏ខ្ញុំដើរសួរគេទៅចំអ្នកស្គាល់គ្នាដែរគេជម្លៀសទៅជាមួយណា ទៅគេសួរថាមីយ៉ុនង៉ែងរកម៉ែង៉ែង ចាសម៉ែខ្ញុំនៅឯណាលួចសួរខ្សិបគេណា ម៉ែខ្ញុំនៅឯណាម៉ែង៉ែងនៅផ្ទះនោះ ទៅដល់ឃើញម្តាយដុតភ្លើងនៅក្រោមផ្ទះ ដុតភ្លើងឆ្អើរជីដូនចាស់គាត់ឈឺ ដុតភ្លើងទៅក៏ខ្ញុំចង់ស្រក់ទឹកភ្នែករកទៅអោបម្តាយទាំងយំ ម៉ែខ្ញុំរត់មកអោបខ្ញុំទៅគាត់ថា កូនឯងកុំមកទៀតណាកូនប្រយ័ត្នគេវៃចោលគាត់ថា ម៉ែភ័យណាស់ឃើកូនឯងមកម៉ែភ័យណាស់ ចឹងខ្ញុំក៏ថាខ្ញុំទៅវិញហើយម៉ែ វាមិនបាច់ទៅទេកូនចាំម៉ែទៅសុំសហករណ៍គេសុំប្រធានព្រោះប្រធាននោះគេចិត្តល្អ យប់គេឲ្យកូននៅបានមួយយប់សិនចាំព្រឹកឡើងកូនទៅវិញណា ទៅក៏ខ្ញុំម៉ែយកទៅលាក់នៅក្នុងបន្ទប់មិនឲ្យគេឃើញទេ ដល់ជួបព្រឹកឡើងគេម្តាយក៏ទៅប្រាប់គេព្រឹកឡើងគេមកមើលកូនយើងទៅគេចង់ចោតថាខ្ញុំយួន ទៅម៉ែខ្ញុំថាកូនខ្ញុំនេះឯងចឹងកូនអុំឯងម៉េចក៏ដូចយួន អត់ទេកូនខ្ញុំសរតែមួយប៉ុណ្ណោះឯង ទៅប្រធានសហករណ៍នោះគេស្គាល់លៃណាស្គាលបងខ្ញុំដែលនោះធ្លាប់នៅណា ទៅសួរបងខ្ញុំថាប្អូនខ្ញុំប្អូនពៅខ្ញុំក្នុងមួយពូជណឹងសវាតែមួយណឹងឯង ទៅបានគេឲ្យនៅមួយយប់ ឲ្យនៅមួយយប់ទៅក៏ស្រណោះម្តាយណាស់អត់ហ៊ានហូបអង្ករទេក្មួយគេឲ្យអង្ករនោះកន្លះកំប៉ុងនោះព្រឹកល្ងាចពីរនាក់ជីដូនណា ពីរនាក់ម្តាយគាត់ ទៅក៏គាត់លាក់អង្ករគាត់បបរតែមួយស្លាបព្រាទេ គាត់ដើរបេះផ្ទីដើរបេះត្រកួនដើររើខ្យងតាមក្រឡុកមុខផ្ទះគេណា យកមកដំដាក់ស្លរឲ្យគាត់ពិសារទៅគាត់ទុកអង្ករឲ្យកូន២

ដល់ពេលខ្ញុំទៅកូនអើយអង្ករបានប្រហែល៣គីឡូ កូនអើយអង្ករនេះណាម៉ែណាគេឲ្យមកកន្លះ
កំប៉ុងម៉ែបិចទុកឲ្យកូនឯងម្ដងទេតិចៗទៅផ្សំបានប៉ុណ្ណេះឯង ទៅកូនឯងទៅពេលណាតែទៅ
យប់កូនអើយម៉ែខ្លាចសត្វណាស់ ស្វាវាយំណាក្មួយ ស្វានោះវាហែកមនុស្សស៊ីស្វាចចកវាយំខ្ញុំ
គ្រាន់តែលឺស្វាវាយំនាំគ្នារត់ទៅក្រាបក្រោមដើមដំឡូងគេ ទៅដល់ពេលទៅញយៗទៅមកម្ដា
យបើកអង្ករ៣គីឡូ មកដល់យកមកអត់ហ៊ានហូបខ្លួនឯងទេទុកឲ្យប្អូន ខ្លាចប្អូនដើរសុំគេទៅគេ
ចាប់វ៉ៃចោល ទៅក៏ទុកឲ្យប្អូនប្អូននោះក៏ ឃើញបងទៅក៏ទៅកន្លែងនោះអត់មានអ្នកណាឲ្យ
ចូលទេកន្លែងយុវណ្ណណាក្មួយចៅ គេរាល់គ្នាសុំចូលគេអត់ឲ្យចូលទេរកវ៉ៃរកទាត់គ្នាដល់យាយ
ណាដូចមាននិស្ស័យ ដូចថាយាយដូចថាគុណគ្រូជួយចឹងណាដល់យាយចូលទៅ គេសួរថា
មិត្ត មិត្តនោះខ្លាចណាមិត្តសំយោធា មិត្តសំបងមិត្តហេងមកហើយគេថាណាទៅគេថា បងមិត្ត
ហេងហា ខ្ញុំថាចាសបើបងមិត្តហេងឲ្យចូលចុះ ទៅក៏គេឲ្យចូលព្រោះខ្ញុំមិនទាន់បានជួបប្អូនដែរ
ទៅដល់គេដេកនៅអង្រឹង បត់ជើងបានសំពះគេសុំជួបប្អូន ទៅគេថាជួបក៏ជួបទៅអើមិត្តហេង
បងមិត្តឯងមកជួបហើយ ទៅក៏ខ្ញុំលើកដៃសំពះគេអរគុណហើយបង ទៅជួបប្អូនប្អូននោះវាយំ
យំដែលអង្ករ៣គីឡូឲ្យទៅប្អូននោះគេលួចបន្តទៀត ទៅក៏យំរ៉ានហេងណាយំ ទៅក៏ខ្ញុំយំ
ជាមួយប្អូនហើយម៉េចបានយំខ្លាចគេយកប្អូនទៅវ៉ៃចោលណា អូនឯងម៉េចយំគេយកហ្អែងទៅ
វ៉ៃចោលហាហ្អែងប្រាប់អញមកកុំឲ្យអញពិបាកចិត្តមើលហ្អែងយំចេះហ្អែងអត់ឈប់យំចេះអញ
ចង់ដាច់ខ្យលហើយប្រាប់ប្អូន បងចង់ដាច់ខ្យល់ហើយប្រាប់បងមកមានរឿងអីអូនមានរឿងអី
យំពីរនាក់បងប្អូនទល់មុខគ្នាទៅក៏វាប្រាប់ថាអត់មាននរណាយកអញទៅវ៉ៃចោលទេពួកយោធា
ស្រលាញ់អញណាស់ ទៅនែអញអត់ដែលធ្វើអីឲ្យខុស ទៅក៏ម៉េចបានអូនឯងយំថាអង្ករដែល
ម៉ែផ្ញើមកអង្ករហើយនិងប្រហុកលីង ត្រីងៀតមួយដុំប៉ុនមេជើងអញដាក់ទៅមិនដឹងអ្នកណា
លួចស៊ីអត់ទេលួចស៊ីបាត់ហើយ ទៅក៏ខ្ញុំថាឈប់យំទៅអូនចាំបងសន្សំអង្ករបងឲ្យអូនឯងហូប
ព្រឹកឡើងចាំអូនឯងដើរទៅបងណាប្រាប់ប្អូនអូនឯងកុំឲ្យដើរលើថ្នល់ជាតិប្រយ័ត្នគេចាប់អូន
ឯងចេញពីធ្វើការមក អូនឯងដើរបេះព្រលិបេះត្រកួនទៅអូនឯងដើរតាមផ្លូវរទេះទៅព្រោះវា
នៅជិតដែរ ចាំបងបើកបបរមកបងយកមកដាក់និងផ្លូវថ្នល់អាទេះ ហើយអូនឯងឃើញអូនឯង
មកយកទៅឲ្យឯងចុកទៅអូនឯងកាម៉ែលឲ្យបងឲ្យឯងដើរទៅចាំបងទៅយកការម៉ែល អញ
ខ្លាចចុះបងប្អូនមិនង៉ែងទៅង៉ែងមក អញខ្លាចអញអត់អីស៊ីអត់អញទេអញស្រីអញអត់ទ្រាំបាន
ប្អូនឯងប្រុសកុំដើរដូចថាដើរសុំគេខ្លាចគេចាប់ប្អូនបានវ៉ៃចោល ទៅដល់ពេលនេះទៅវារាល់ថ្ងៃ
ដើរមករកខ្ញុំ ដើរមកខ្ញុំខ្ញុំបើកបបរឲ្យកន្លះការម៉ែល កន្លែការម៉ែលខ្ញុំដុសតែបន្តិចទេទុកអាកន្លះ
ការម៉ែលយកទៅផ្លុងឲ្យប្អូនរាល់ថ្ងៃ ផ្លុងឲ្យប្អូនរាល់ថ្ងៃទៅក៏ ខ្លួនឯងយកមកដល់បេះផ្ទីយកមក
ដាក់បបរស៊ីផ្អែតមិនផ្អែតទ្រាំរាល់ថ្ងៃចុះឯង ប៉ុន្តែអត់ដែលដើរហ៊ានដូរគេទេ សុខចិត្តអត់ស្គម

ដូចស្បូវកណ្តាបទៅក៏ថ្ងៃនោះឯងទៅនេគេឲ្យទៅកាប់ដី កាប់ដីទៅប្អូននោះវារកបងអត់ឃើញ ណា ទៅរស់តែចុះរើសនែវរស់តែឃើញត្រី កូនត្រីអណ្តែងមួយកន្លងអាល័យតែបោចឲ្យបង ដល់ខ្ញុំចាំប្អូនយូរពេកអត់មានបានទុកបបរឲ្យប្អូនទេដំឡូងគេឲ្យប៉ុននេះឯងប្រហែលមួយច ង្កាមដាក់នៅលើដើមត្របែកព្រៃទុកឲ្យប្អូនិងការម៉ែលរស់តែអង្គុយទៅបេះនេស្អីទេយកមកស៊ី ទំងន់ពោះណាបេះល្ពាក់យកមកហូប ដល់អាប្អូនដើរមករកអញនៅនេះឯងប្អូន អញនៅនេះ ឯងអញស៊ីបបរអស់ហើយអាអូនអត់ឃើញអូនឯងមក ចុះវាដល់ពេលគេធ្វើការទៅហើយនោះ ទៅក៏វាថាអត់ក៏អត់ទៅ អញបានដើមព្រលិតរំចង់អញយកទៅបបរស៊ី នែអញខំបោចត្រីគេ បានត្រីអណ្តែង នេះយកទៅអូនឯងយកទៅទុកបបរទៅទៅវាថា ទេយកទៅចាំអញទៅរក ទៀតទៅក៏រត់ទៅរកដំឡូងប៉ុនកដៃយកមកឲ្យប្អូនគេយកស៊ីអស់ទៅទៀតទៅក៏នាំបងប្អូន អង្គុយយំខ្ញុំយំប្អូនខ្ញុំថាកុំយំ ខ្ញុំយំអាណិតប្អូនណាដែលប្អូនធ្លាប់មកបានស៊ីណាទៅគេថាកុំយំអី ណោះយកត្រីទៅអញបានព្រលិតហើយបែបថ្ងៃនេះអញមិនបានធ្វើការទេមើលថ្ងៃស្មើនេះ ហើយ ថាទៅៗអូនធ្វើមិនធ្វើអូនឯងទៅឲ្យដល់កន្លែងកុំឲ្យគេថា ទៅក៏ប្អូនដើរទៅវិញខ្ញុំក៏បាន ត្រីអណ្តែតប្អូនមកខ្ញុំអង្គុយប៉ិចអាអណ្តែងនោះវាមុតដៃទៀតក្ហួយអើយក្ហួយភ្លៀងស្រិចៗក៏វា ចុក យំនិងអណ្តែងណឹងមួយថ្ងៃរ៉ល់ល្ងាចធ្វើការឲ្យគេបណ្តើយំបណ្តើរទៅក៏ពួកប្រធានគេសួរ ថា មិត្តយ៉ុនម៉េចបានមិត្តឯងយំអត់ហ៊ានតែអណ្តែងមុតទេថាខ្យាទិចយើងធ្វើការឲ្យគេថាខ្យាដំរី វាទិច បើថាអណ្តែងគេកសាងយើងណាកូន ថាខ្ញុំខ្យាដំរីទិចកាយដីមិញខ្យាដំរីទិចទៅគេថាហឺ បើខ្យាដំរីទិចមិត្តឯងពឹតខ្លាំងនោះវាហើមថាខ្ញុំពឹតឡើងយំ ទៅគេថាចុះទៅសម្រាកទៅបើឈឺ ហើយ សម្រាកនោះគេមកឲ្យកន្លែងទេណាកូនគេឲ្យនៅនោះឯងហាលភ្លៀង ខ្ញុំយំរហូតដល់ ដេកលក់រហូតដល់មិត្តគេដាស់ថាមិត្តឯងយំហើយបាត់ឈឺហើយខ្ញុំថាបាត់ហើយមិត្តនោះ ប្រធាននោះគ្នាយើងទេដែលគេលើកលែងទោសឲ្យណាទៅក៏មកវិញទៅក៏គេឲ្យយើងនៅ កន្លែងគ្នា៣០០នាក់នៅសល់តែគ្នា៧០នាក់មិនដល់៧០នាក់ផង ប្រហែលជា៣០នាក់គេយក ទៅវ៉ៃចោលក្ហួយអើយរាល់ថ្ងៃនៅកន្លែងនោះបារម្ភណាស់ យាយបារម្ភណាស់ម៉េចបានថា យាយបារម្ភ យប់ឡើងកម្មាធិបាលគេមក ប៉ះថ្ងៃនោះខ្ញុំង្ងូតទឹកខ្ញុំសំណាងហើយអាយុខ្ញុំវែងមុជ ទឹកចងពុងឃោធាគេមកដល់ មើលដល់ភ្លាមគេដើរតាមខ្ញុំ តាមខ្ញុំភ្លាមតាមខ្ញុំភ្លាមខ្ញុំរត់ចូលក្នុង សាលាកេសេល ខ្ញុំរកចូលក្នុងសាលាកេសេលទៅ គេថាសួរថាមិត្តនារីណាមិញចងពុងមុជទឹក មិញ ខ្លាចណាស់ថាស្រលាញ់អ្នកណាចាប់អ្នកនោះឯងយកទៅធ្វើបានហើយសម្លាប់ចោល ទៅក៏ខ្ញុំរត់ទៅពួនទៅក៏ពួកនោះជួយលាក់ បើប្រាប់ខ្ញុំងាប់ណាថ្ងៃណឹង ទៅក៏ថាមិត្តណាទេបង មិនដឹងទេថាចេះឯង ទៅចេញពីខ្ញុំទៅក្រុមទីន្មានទី៣ ទៅដល់ហៅសួរថាមិត្តនារីមានមិត្តណា ប្រធានទេថាមាន មានបងអីទេនៅអារញ្ញាយើងនេះ តែគាត់ចាស់ ទៅគេហៅទៅដល់គេហៅ

ទៅមិត្តនោះចាស់គេអត់យក គេឲ្យមកហៅប្រធានមានប្រធានផ្សេងគេហៅបងលុំ បងលុំស្អាតណាស់គាត់សិស្សសាលាយកគាត់ទៅ បែបធ្វើបាបហើយវាកាត់កដាក់ផ្សេង យកខ្លួនកាប់ដាក់ផ្សេងទៅក៨ពួកខ្ញុំនេះថាពួកនោះថាមិត្តយ៉ុនឯងឃើញទេសំណាងណាស់មិត្តយ៉ុនឯង ឃើញមិត្តយ៉ុនឯងចូលផុតឥឡូវនេះគេហៅបងលុំទៅបាត់ហើយគេថាណា ថាហៅមិត្តលុំធ្វើអីចុះមិនដឹងទេទៅខាងក្រោយផ្ទះណឹងឯង ទៅស្រាប់តែបាត់មួយយប់វលព្រឹកស្រាប់តែព្រឹកឡើងលឺសូរគេថាពួកអ្នកស្រុកណឹងណា តំបន់ចាស់ថាគេឲ្យប្រធានភូមិនោះឯងគេហៅប្រធានសហករណ៍ ប្រធានសហករណ៍ទៅកប់ខ្មោច ខ្មោចពួកនារីកសាងខ្លួនគេនិយាយខ្សិបគ្នាណា ទៅក៏ពួកខ្ញុំបាត់គាត់យូរបាត់គាត់យូរអត់ឃើញរហូតដល់ថ្ងៃនោះឯងនាំគ្នាទៅច្រូតស្រូវ ច្រូតស្រូវនោះច្រូតតាមជើងថ្នល់ជាតិចេះ ច្រូតតាមជិតថ្នល់ជាតិទៅក៏មិនឆាយមួយស្រករគ្នានោះមិត្តឆាយនោះថា វើយឈឺបទជើងណាស់ហ្អែងសុំទៅបត់ជើងមួយភ្លែតទៅបត់ជើងក៏យើងសុំគេដែរកូនទៅបត់ជើងមួយភ្លែតទៅដល់បត់ជើង ទៅបត់ជើងទៅចាំខ្មោចដែលគេកប់ណឹង កប់នោះចចកអីវាកាយ ទៅវាអត់ខ្លាចវាយកឈើកាយៗទៅវារត់មកវិញ រត់មកវិញថាពួកនេះកុំឲ្យលឺមាត់ចាំពេលហូបបាយយើងទៅមើលខ្មោច អញសង្ស័យតែខ្មោចបងលុំវាថាណា បងលុំនោះគាត់សិស្សសាលាថ្នាក់ទីបញ្ចប់ណាទៅមើលខ្មោចបងលុំ មិនដឹងខ្មោចណាទេខ្មោចបងលុំអញសង្ស័យស្រាប់ដល់ពេលគេឲ្យហូបបាយទៅថាធ្វើទៅនាំគ្នាបេះរពាក់បេះអីណា បើយើងមិនប្រាប់គេចុះថាទៅមើលខ្មោចខ្លាចវាឆោរឡោរទៅគេសម្លាប់យើងចោលទៀត ទៅក៏ទៅមើលខ្មោចទៅក៏កាយមើលខ្មោចបងលុំមែន កាយរកមើលក្បាលអត់ឃើញវាកាប់ក្បាល់ដាច់ផ្សេងខ្លួនកប់ផ្សេងកុំអីក៏អត់ចំណាំដែលកូនចំណាំសំពត់ស សំពត់សអាជំនាន់អាពតមានអីស្លៀកគាត់ដេរសំពត់សមួយបំណាស់ទៅសពត់ខ្មៅមួយបំណាស់ដេរជាប់គ្នា ទៅក៏ឃើញ ឃើញខ្មោចគាត់ទៅក៏នាំគ្នាខ្ញុំណឹងខ្លាចខ្មោច ខ្ញុំដើរទៅចាប់ដៃចុះតូចជាងគេនោះ ដើរតាមដៃនារី នារីទាំងអស់គេធំជាងយើង ក៏ដើរចាប់ដៃគេពួកនោះគេថាង៉ែងខ្លាចអីខ្ញុំខ្លាចខ្មោច ចាប់ដៃគេក៏វិញក៏យប់ឡើងដេកអត់ដែលលក់ទេ យប់ឡើងចេះណាគេដើរឆ្វែលជុំវិញផ្ទះយើងជុំវិញកន្លែងកំពង់ក្តីណាក្មួយ មើលតែអាណាស្អាតវាយកទៅធ្វើបាបរួចវាសម្លាប់ចោល ប្រធាននោះឈ្មោះអីទេអ៊ុំភ្លេចបាត់ទៅហើយ ទៅក៏វាយកទៅសម្លាប់ចោល នារី៣០០នាក់មួយថ្ងៃ២នាក់ ១នាក់ ២នាក់រាល់ថ្ងៃហើយយើងយប់ឡើងខ្ញុំនេះអីយប់ឡើង មកពីធ្វើការអត់ហ៊ានដើរអត់ដែលហ៊ានចេញមកក្រៅទេ ចេញមកក្រៅប្រធានខ្ញុំប្រាប់ទៅកុំចេញក្រៅតែហ៊ានចេញក្រៅប្រយ័ត្នបាត់ខ្លួនហ្អែង ចេញក្រៅប្រយ័ត្នបាត់ខ្លួនទៅខ្ញុំមិនដែលហ៊ានចេញទេយប់ឡើងហូបបាយរួចទាញភួយបានទទូដេកហើយពួកមិត្តខ្ញុំមិត្តនារីៗប្រធានខ្ញុំប្រាប់ថាបើគេហៅយប់អីកុំចេញឲ្យសោះគេប្រាប់ណា បើឃើញយើងស្អាតហើយវាយកទៅធ្វើបាបហើយវាសម្លាប់យើងចោលហើយ

រាល់ថ្ងៃរយៈប្រហែលជា៣ខែ ៣ខែពួកអាពតនេះវៃដាច់អត់ទាល់ដល់ទេកូន មើលរយៈ៣ខែគេជម្លៀសទៅទៀតគេជម្លៀសទៅភ្នំពោរប្រហោងទៅនៅជុំម្ដាយណា ដល់ទៅនៅកន្លែងនោះបានកំសត់ទៀតកូនគេឲ្យធ្វើស្រែដកស្ទូង គេក៏គេវាជីករណ្ដៅវែងជុំវិញវាជីកប្រុងសម្លាប់យើងនោះ នៅតែ៣ថ្ងៃទៀតវាវាយយើងដាក់ក្នុងអន្លុងណឹងហើយដល់ពេលពួកខ្ញុំនេះគេយកម្ដាយដល់ពេលគេដាក់ទៅដល់ពេលថ្ងៃនោះវាថាខ្វះ ខ្វះក្រុមកុមារជំទើរទៅនៃច្រូតស្រូវវាថាណាទៅក៏ខ្ញុំនេះម៉ែគាត់ថាកុំទៅដឹងកូនគេដូចថាអង្គការគេដាក់ហើយយើងមិនទៅមិនកើតណាម៉ែគាត់ថា ទៅៗនៅតែប្អូនពៅនៅជាមួយម្ដាយ ទៅខ្ញុំនេះគេយកទៅដាក់ឲ្យច្រូតស្រូវនៅកំពង់ក្ដី ច្រូតស្រូវនៅកំពង់ក្ដីនោះឯងនៅរយៈបានប្រហែលជា រយៈបានប្រហែលជា១ខែបានវៀតណាមរំដោះ  ពេលដែលវៀតណាមរំដោះហើយអត់ហ៊ានចេញទៀត គេចេញព្រៀតគ្រប់គ្នាខ្ញុំគេអត់ឲ្យមកផ្ទះពួកឃោធាអត់ឲ្យមកផ្ទះបានគុណរ៉ូន ជនបងអាអ្នូន អឺមិត្តអើយឲ្យមិត្តយ៉ុនទៅថាអត់ទេខ្ញុំអត់ឲ្យទៅទេ គេម៉េចក៏ឲ្យទៅបានម៉េចខ្ញុំមិនឲ្យទៅ ខ្ញុំឆ្ងល់ណា វាថាមិត្តឯងចាំទៅជាមួយខ្ញុំទៅផ្ទះខ្ញុំសិនគេថ ខ្ញុំថាទេខ្ញុំអត់ទៅទេខ្ញុំទៅផ្ទះម៉ែខ្ញុំជួបម៉ែខ្ញុំហើយ ឲ្យខ្ញុំទៅៗវាអត់ឲ្យទៅទេវាអង្គុយឃាំងមុខទ្វារ បានរ៉ូន ជននេះឯងថា ឲ្យវាទៅៗមិត្តអើយម៉ែវានៅចាំហើយមើលឡើងម៉ោង៣ ម៉ោង៩ទៅហើយ ទេអត់ទេមិត្តឯងទៅៗ មិត្តយ៉ុនចាំឲ្យទៅផ្ទះជាមួយខ្ញុំគេថា ទៅខ្ញុំថាខ្ញុំអត់ទៅទេខ្ញុំទៅម៉ែខ្ញុំហើយខ្ញុំថាណាទៅក៏ ស្រាប់តែដល់តិចពួកឃោធានារីៗមកដល់ថា មិត្តផងមិត្តឯងម៉េចមិនរត់គេថាណាមិត្តឯងអង្គុយធ្វើអីទៀត វៀតណាមចូលដល់ស្ពឺស្នោងហើយគេហៅពួកខ្មាំង ពួកខ្មាំងបុកចូលដល់ស្នោងហើយ ទៅវាអត់ចង់ទៅទេទាល់តែវាទៅបានខ្ញុំបានមកណាក្មួយ វាអត់ឲ្យយើងមកវាថាឲ្យយើងទៅនៅផ្ទះជាមួយវា ហើយខ្ញុំទៅនៅផ្ទះឯណាបើគេទៅម៉ែគេអត់ហើយយើងនៅធ្វើអីទៀតយើងទៅស្គាល់ជីដូនជីតាអីវា ទៅក៏បានមកយប់ដើរមកដើរមកប្រហែលជាម៉ោង៩ទៅរកម្ដាយ ដើរចឹងទៅរកម្ដាយដើរតាមដែលវត្តវិហារព្រហ្មណា ទៅរកម្ដាយម្ដាយចាំកូនគេចេញឡើងអស់រលីងម៉ែខ្ញុំនៅតែ៣នាក់ទេនៅតែ៣នាកម៉ែកូនទៅក៏ដាច់ចិត្តមករកកូននិងកន្លែងនៃស្ពឺគេហៅស្ពឺស្ពានត្នោតដាច់ចិត្តមករកកូននៅស្ពានត្នោតគេទៅអស់គេមកស្រុកអស់គ្រប់គ្នា ទៅគេថាយាយឯងនៅដល់ណាទៀតយាយឯងម៉េចក៏មិនទៅខ្លាចគេអ្នកសម្លាប់ ទៅគាត់ថាចាំកូន យាយឯងគេថាកូនទៅឯណាគាត់ថាកូនគេជម្លៀសទៅស្ពានត្នោត ទៅក៏ម៉ែខ្ញុំគាត់ដើរមកជាមួយចៃឡានក៏ដើរមកជួបកូន ជួបកូនក៏នាំគ្នាដើរបកទៅស្ពានត្នោតវិញ ស្ពានត្នោតទៅក៏បកទៅរកបងនៅល្វែងឬស្សីបានផុតពីនោះមក បាននាំគ្នាដើរមកតាផ្លូវមកផ្ទះណឹងមកស្រុកណឹងឯង។

ក៖ ចុះម្ដាយយាយមានឈ្មោះអ្វីដែរយាយ?

ខ៖ យាយមឿន។

ក៖ ចុះឪពុកឈ្មោះអ្វីដែរ?

ខ៖ ឪពុកឈ្មោះវ៉ន។

ក៖ ចុះពួកគាត់ទាំងពីរនាក់ណឹងមានស្រុកកំណើតនៅឯណាដែរ?

ខ៖ នៅស្រុកនេះឯងជាមួយគ្នា។

ក៖ ចុះម្ដាយរបស់យាយជាមនុស្សកាច ឬក៏ស្លូតដែរយាយ?

ខ៖ យ៉ាគ្រាន់ដែរ កាចដែរសួរយាយវ៉ាតទៅបានដឹង ពួកគាត់។

ក៖ ចុះឪពុករបស់លោកយាយវិញ?

ខ៖ ប៉ាក៏កាចដែរប៉ុន្ដែគាត់អ្នកធ្វើការពីសង្គមណា តែគាត់កាចគាត់យល់ញាតិណាស់គាត់អត់ដែលមានកាចតែពីសតែពាសទេ គាត់យល់ញាតិ។

ក៖ ចុះម្ដាយហើយនិងឪពុកលោកយាយធ្វើការអ្វីដើម្បីចិញ្ចឹមជីវិតយាយ?

ខ៖ ពីដើមហា?

ក៖ បាទ។

ខ៖ ពីសង្គមគាត់ធ្វើចំការចំការសណ្ដែកចំការឪឡឹកនៅស្រុកនេះឯង។

ក៖ អត់មាននេសាទអីទេ?

ខ៖ អត់ទេ អត់ចេះទេ។

ក៖ ចុះយាយចាំជីដូនជីតាខាងម្ដាយទេយាយ?

ខ៖ ជីដូនជីតាខាងម្ដាយចាំ។

ក៖ បាទឈ្មោះអ្វីដែរយាយ?

ខ៖ ជីដូនឈ្មោះម៉ាមុល ជីតាឈ្មោះកុងឆេង ខាងឪពុកឈ្មោះយាយមរ តាតួន។

ក៖ ពួកគាត់ណឹងក៏ជាអ្នកនៅស្រុកនេះដែរ?

ខ៖ នៅស្រុកនេះឯង។

ក៖ ចុះកាលដែលយាយកើតមកណឹងយាយទាន់យាយតាទេ?

ខ៖ អត់ទាន់ ទាន់តែជីដូនមួយជីដូនខាងម្ដាយ ជីដូនខាងម្ដាយណឹងដែលសែងគាត់កាត់ព្រែកប្រោសនោះដែលគាត់ពិការនោះ។

ក៖ ចុះយាយមានបងប្អូន ឬក៏សាច់ញាតិដែលរស់នៅក្រៅប្រទេសអត់យាយ?

ខ៖ អត់ កុំថាមានវាអត់ទៅហើយព្រោះវាគេមិនដែលទាក់ទងយើង មានមែនជីដូនមួយមែនតែគេមិនដែលរាប់រកយើង យើងក៏មិនដែលរាប់រកគេ។

ក៖ ចុះស្វាមីរបស់យាយមានឈ្មោះអ្វីដែរយាយ?

ខ៖ ឈ្មោះសេង ហាយ សេង ហុង នាមត្រកូលគាត់សេង ហុង។

ក៖ ហើយយាយបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីណឹងនៅឆ្នាំណាដែរ? ហើយរៀបបានប៉ុន្មានឆ្នាំហើយបើគិតដល់ឥឡូវ?

ខ៖ មើលចូលស្រុក ចូលស្រុកបានមួយឆ្នាំ

ក៖ ចឹងរៀបនៅឆ្នាំ១៩៨០?

ខ៖ ណឹងឯង។

ក៖ ចឹង៥០ឆ្នាំហើយ?

ខ៖ ណឹងឯង៥០ឆ្នាំ

ក៖ ចុះកាលយាយរៀបការណឹងយាយអាយុប៉ុន្មានដែរ?

ខ៖ អាយុ២០ឆ្នាំ។

កៈ ចុះអាពាហ៍ពិពាហ៍ណឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ ឬក៏រៀបចំដោយចិត្តខ្លួនឯងដែរកាលណឹងយាយ?

ខៈ និយាយទៅកុំឲ្យខ្មាស់គេមិនចង់និយាយទេ វាវេទនា ដូចថាគាត់ដណ្ដឹងយើងយើងអត់យកគាត់ណា និយាយតែប៉ុណ្ណឹងយល់។

កៈ យាយចេះអាន និងចេះសរសេរអក្សរខ្មែរទេយាយ?

ខៈ អត់ចេះសរសេរ ចេះតែមួយមើល។

កៈ ចឹងមានរៀនទេកាលនៅក្មេងយាយ?

ខៈ កាលនៅក្មេងរៀនបានអាយុ១០មើលរៀនអាយុ១០ឆ្នាំឪពុកស្លាប់ ឪពុកស្លាប់តាំងពី១០ឆ្នាំទៅក៏ឈប់រៀន។

កៈ ហើយកាលរៀនណឹងរៀនដល់ថ្នាក់ទីប៉ុន្មានដែរយាយ?

ខៈ កាលនោះមើលពីដើមមិញយើងហៅថាថ្នាក់ទី៣ ថ្នាក់ទី១១ ថ្នាក់ទី១២ ១១ ១០ ថ្នាក់ទី៣។

កៈ ចុះកាលរៀនណឹងរៀននៅសាលាដែរយាយ?

ខៈ សាលានៅភ្នំក្រោម។

កៈ ចុះយាយមានចេះភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរអត់យាយ?

ខៈ អត់ចេះតែភាសាខ្មែរ។

កៈ ចុះយាយមានមិត្តភិក្តដែស្និតស្នាលដែលធំធាត់មកជាមួយគ្នាមកដល់ឥឡូវមានអត់យាយ?

ខៈ មិត្តស្និតស្នាលមានតែអ្នកក្នុងស្រុក។

កៈ បាទ។

ខៈ មានដូចថាមិត្តជិតស្និតនោះ ពីជំនាន់អាពតមកក៏ចេះតែស្រលាញ់គ្នាទៅចេះតែរាប់អានគ្នាទៅវាមានច្រើន ប្រពន្ធប្រធានឃុំយើងនេះមួយហើយនៃ ច្រើនណាស់ក្មួយ។

កៈ អាចរៀបរាប់បន្តិចមកថាអ្នកណាខ្លះដែរ?

ខៈ ព្រែក  យាយព្រម យាយរ៉េត យាយមួន  ហើយផុតពីនោះស្គាល់ធម្មតា។

កៈ ចុះយាយមានអនុស្សាវរីយ៍អ្វីខ្លះដែរជាមួយមិត្តភិក្តជិតស្និតដែរ?

ខៈ អនុស្សាវរីយ៍ជំនាន់អាពត ធ្លាប់អត់ស៊ីជាមួយគ្នាបានចែកគ្នាស៊ីបានអំបិលប្រហុកចែកគ្នាលួចលាក់ទៅ ដូចថាខ្ញុំអត់ចេះទៅ មកពីធ្វើការទៅឃើញនេះមានអីស៊ីហើយអញគេឲ្យអំពិល អញមានអីហូបហើយ អញគេឲ្យអំបិលតិច ស៊ីមិនឆ្អែតទេហ្នែងអើយពីដើមមិញគេហៅហូប ណាហូបមិនឆ្អែតទេទៅក៏យកអំបិលមកឲ្យ ហាខ្លះគេថាង៉ែង មិត្តយ៉ុនមិត្តឯងចេះហូបសាច់ឆ្កែដែរ ខ្ញុំអត់ចេះហូបទេដូចថាគេបានមកពីណាពីណាីណាទៅអត់ ទៅក៏កំសត់កម្រដេកមុងជាមួយគ្នាទៅ ប្រលែងគ្នាទៅដូចថាកាលនោះវាភ័យផងព្រួយផងណាហើយក្មេងនៅក្នុងការសប្បាយ ដូចថាចេញពីមុខមិត្តទៅណាប្រលែងគ្នាទៅណាទៅក៏បានដល់មកសព្វថ្ងៃក៏នៅតែរាប់អានគ្នាដែរ ឃើញចេះតែឲ្យថ្ងៃណាខ្ញុំអត់ចេះទៅគេឲ្យង៉ែងមានអីស៊ីអត់ អត់ទេហ្នែងអត់ប្រហុកស៊ីគេលួកប្រហុកឲ្យមកមួយគីឡូមក ថ្ងៃណាគ្នាអត់ទៅក៏យើងឲ្យម៉ាំគ្នាវិញទៅណា។

កៈ ចុះយាយធ្លាប់ធ្វើស្រែចំការទេយាយ?

ខៈ សព្វថ្ងៃហី?

កៈ អត់ទេតាំងពីក្មេងដល់ឥឡូវ?

ខៈ តាំងពីក្មេងនៅជាមួយឪពុកធ្វើជាមួយម្តាយធ្វើចំការសណ្តែកចំការឪឡឹកដល់មកសព្វថ្ងៃអត់ទេ។

កៈ ចុះកាលនៅសម័យប៉ុល ពតយាយគេឲ្យធ្វើស្រែអត់?

ខៈ ធ្វើគេធ្វើស្រែគេជម្លៀស គេជម្លៀសយើងទៅណឹងឯងមិនឃើញប្រាប់ក្មួយថាវាវេទនាណាស់។

កៈ ចុះតាំងពីក្មេងដល់ឥឡូវតើយាយធ្លាប់ប្រកបការងារអ្វីខ្លះដែរដើម្បីចិញ្ចឹមជីវិត?

ខៈ មិនដឹងទៅរកទេក្មួយសព្វថ្ងៃអត់កុហកទេ តាំងពីក្មេងដល់ចាស់មិនមានពេលស្រណុក ចុះប្តីនៅធ្វើការឃុំកាលពីដើមដែលគាត់អត់ទាន់ខូចណាគាត់នៅធ្វើការឃុំទៅក៏យើងក៏ដើរលក់

ត្រប៉ែលក់ពោត ចិញ្ចឹមប្ដីរកមួយថ្ងៃបានចំណេញអង្ករព្រឹកល្ងាចមួយគីឡូ ២គីឡូគ្រប់តែកូន ដល់ពេលឥឡូវដូចថាធូរតិចដែលយើងឡើងមកនៅលើយើងបានរកបបរកកូនធំទៅ ស៊ី ដោយសារកូនខ្លះទៅយើធ្វើស្រែខ្លះទៅ ដល់ឆ្នាំនេះមិនបានធ្វើទេអត់ដើមអត់ចុង រាល់ថ្ងៃឈឺ អត់មានជាទេឈឺ រាលថ្ងៃដើរលក់ពោតសួរតែក្នុយទៅដឹងហើយ ដើរលក់ពោតរាល់ថ្ងៃពោត នោះមួយថ្ងៃបានចំណេញ៥០០០អត់កុហកទេ ចំណេញ៥០០០ទៅថៅពេញផ្ទះកូនអាធា កូន អាសិលា កូនកាប៉ុល កូនអាធិដែលឪម៉ែគ្នាអត់ណាទៅគ្នាយកមកធ្វើ គ្នាយកមកធ្វើឪពុកគ្នាទៅ រកស៊ីទៅក៏នៅលើយើង ឃើញថាព្រឹកមិញអត់កុហកទេសល់លុយ១០០០ ១០០០មែនណា ថៅយាយអត់កុហកទេយាយសុំសីល សល់លុយមែន១០០០ទេសល់លុយមើល៣០០០ ៤០០០នោះយាយទៅវត្តយាយដាក់សីលនោះអស់១០០០ ដាក់សីលអស់១០០០យាយមក វិញយាយ ឲ្យអាថៃ២នាក់បងប្អូនវានោះ១០០០ ឲ្យអាហ្សូរនិងមីបុប្ផានោះ១០០០ នៅសល់ ១០០០មិនដឹងជាធ្វើអីទេឲ្យមីពៅ ម៉ាក់ធ្វើអីហូបអីកូនអើយម៉ែមាន១០០០មិនដឹងធ្វើអីទេកូន បុកអំបិលម្ទេសទៅកូន ឲ្យថៅស៊ីទៅទឹកស៊ីអីវដាក់ឲ្យប្អូនស៊ីទៅ ទៅក៏គេថាអូយម៉ាក់អើយខ្ញុំ លេបអត់រួចទេ ចុះវាធ្លាប់ស៊ីឆ្ងាញ់ម៉ាក់អើយខ្ញុំលេបអត់រួចទេម៉ាក់ ក៏កូនអើយធ្វើអីខ្ញុំមាន១០០០ ១០០០គេទៅទិញនែ បន្លែ១៥០០គេទិញពទទាមួយគេលក់មួយមកគេហូប បានឆ្អែតមួយពេ ល។

ក៖ ចឹងតាំងពីក្មេងរហូតមកដល់ពេលនេះតើពេលណាដែលយាយគិតថាសប្បាយចិត្តជាងគេ ដែរយាយ?

ខ៖ ពេលណាដែលសប្បាយទាល់តែកូនវាធូរបានម៉ែសប្បាយ ចុះបើកូននៅតែក្រកូនអត់ សប្បាយទេ ទាល់តែកូននោះដូចថាវាមានមុខរបររកវាមាន ដូចថាមានផ្ទះមានសំបែង ត្រឹមត្រូវ នៅរាងខ្លួនណា នោះបានថាវាសប្បាយចុះវាមកនៅជាន់កនេះហេតុតែម្ដាយមានផ្ទះឲ្យនៅ ណា បើសិនអត់គ្នាវេទនាដល់តែក្បូរ៉ូណាចេះទៀតបើគ្នាមិនប្រឹងទៅបានអីឲ្យកូនហូប។

ក៖ ចុះតាំងពីក្មេងដល់ពេលនេះតើជីវិតយាយមានការផ្លាស់ប្ដូរអ្វីខ្លះដែរយាយ?

ខ៖ មានផ្លាស់ប្ដូរខ្លះដែរមិនមែនថាយើងទុក្ខរហូតទេណាកូន មានកាលដែលយាយនៅទន្លេ យាយកម្ម ណាដល់យាយឡើងមកនៅនេះវាមានសប្បាយចិត្តខ្លះមានថ្ងៃសប្បាយមានថ្ងៃទុក្ខ បានថាមិនមែនទុក្ខរហូតទេវាមានថ្ងៃសប្បាយថ្ងៃទុក្ខ ថ្ងៃណាក៏រកកាលតានៅទៅវាចេះតែមាន លុយចាយបបូរ ដល់តាគាត់ឈឺរយៈ៧ខែអស់លុយពីខ្លួន យាយកើតទុក្ខតែមិនដឹងថ្ងៃណានិង ចប់កើតទុក្ខទេ។

កៈ តាំងពីក្មេងមកយាយមានក្ដីស្រម៉ៃធំឡើងចង់ធ្វើអ្វីទេយាយ?

ខៈ ក្ដីស្រម៉ៃចង់ធ្វើអីក្ដីស្រម៉ៃចង់តែរកស៊ីឲ្យបានមានដូចគេកុំឲ្យក្រគេមើលងាយ បានជាយាយប្រឹងតាំងពីបានប្ដីកាលយាយនៅជាមួយម្ដាយយាយស្រណុកយាយអត់កុហកទេ ឪម៉ែយាយស្រណុកយាយមិនដែលធ្វើអីទេ ដល់តែពេលយាយចាស់ចាប់បានប្ដីក៏យាយវេទនារហូត មិនមែនរហូតទេមានវគ្គណាមានវគ្គណាក្រមានថ្ងៃណានោះក៏ដាច់ទៅមានថ្ងៃណានោះក៏បបរូណ៍ទៅ។

កៈ ចុះយាយចូលចិត្តពិសារម្ហូបអ្វីដែរយាយតាំងពីក្មេងដល់ឥលូវ?

ខៈ ម្ហូបពីក្មេងដល់ឥលូវដែលយាយចូលចិត្តនិយាយទៅដូចថាបើរឿងចំណីវិញយាយ អត់សូវចូលចិត្តអីទេចូលចិត្តតែមីកន្ទាំងបើកូនថាយាយចូលចិត្តតែរបស់ថ្លៃ បើថាបានមីងកន្ទាំងរាល់ថ្ងៃសប្បាយចិត្តណាស់ហូបតែចុះឯង កាលអាធាគេដឹកភ្ញៀវពេលគេបើកលុយបានមីកន្ទាំងយប់ឡើងមួយកញ្ចប់ យប់ឡើងមួយថង់អាធាគេទិញយកមកឲ្យ ម៉ាក់តែបើទិញអីមកអត់ចូលចិត្ត ដូចថានំបញ្ចុកសម្លរគីរីអីយកទៅឲ្យឆ្ងាយទៅ បើថាកូនមីកន្ទាំងមកអរណាស់យប់ស្មាណាក៏ងើយហូប។

កៈ ចុះតាំងពីក្មេងមកយាយចូលចិត្តស្ដាប់បទចម្រៀងអត់យាយ?

ខៈ ចូលចិត្តណាស់រឿងចម្រៀង។

កៈ ចូលចិត្តស្ដាប់ចម្រៀងអ្នកណាដែរយាយ?

ខៈ ចូលចិត្តរស់ សេរីសុទ្ធា ស៊ិន ស៊ីសាមុត ប៉ែន រ៉ន អ៊ឹង យ៉េង ។

កៈ ចុះយាយមានចាំបទណាដែលយាយចូលចិត្តជាងគេអត់? ចំណាងជើងបទចម្រៀងណា?

ខៈ ចំណាងជើងដូចថាសព្វថ្ងៃដូចមិនសូវចាំបើថាគេច្រៀងស្គាល់ទាំងអស់ ចេះទាំងអស់ចម្រៀងឲ្យតែបទពីសង្គមចេះទាំងអស់។

កៈ ចុះយាយកាលពីក្មេងៗធ្លាប់បានលេងល្បែងប្រជាប្រិយខ្មែរអីទេពេលចូលឆ្នាំ?

ខៈ អត់ចេះលេង អត់ចេះរាំ ទើបតែចាស់ហើយចេះរាំ ចេះរាំនិងខូចចិត្តកូនងាប់មួយទៅចេះរាំតែសព្វថ្ងៃឈប់រាំហើយចៅ។

ក៖ អញ្ចឹងមកដល់ចុងបញ្ចប់នេះតើយាយមានអ្វីចង់ផ្ដាំផ្ញើកូនចៅជំនាន់ក្រោយរបស់យាយទេ? ថាពួកគេគួរតែរស់នៅបែបណា ធ្វើមនុស្សបែបណាដែរយាយ?

ខ៖ ខ្ញុំសូមផ្ដាំផ្ញើទៅឲ្យកូនចៅជំនាន់ក្រោយ សូមឲ្យធ្វើជាមនុស្សល្អកុំប្រព្រឹត្តពាលា អាវ៉ាសែ ឆក់លួចប្លន់ ហើយនិងជក់ម៉ា ផឹកស្រា សុំឲ្យធ្វើជាកូនល្អគ្រប់ៗគ្នាទាំង មួយប្រទេសកម្ពុជាយើងទាំងអស់សូមឲ្យធ្វើកូនល្អ សូមសុខសប្បាយ ហើយជៀសវាងជាពិសេសគឺជៀសវាងពីគ្រឿងញៀន មែនស្អប់ណាស់គ្រឿងញៀនយាយស្អប់ណាស់ចៅ សូមឲ្យអង្គការជួយណែនាំកូនចៅនៅប្រទេសកម្ពុជាយើងកុំឲ្យមានប្រព្រឹត្តនៅអំពើពុករលួយដូជាគ្រឿងញៀន វាគ្មានបានប្រយោជន៍ទេបានតែបំផ្លាញជីវិតរបស់ខ្លួនឯង និងសុខភាពល្អខ្លួនឯង ខ្លះទៅជាឆ្កួត ខ្លះទៅជាឈឺ ភ្លេចម៉ែភ្លេចឪ សូមតែប៉ុណ្ណោះឯងកូន។

ក៖ បាទខ្ញុំសូមអរគុណដល់យាយដែលបានចំណាយពេលវេលាសម្ភាសន៍ជាមួយខ្ញុំ ខ្ញុំសូមជូនពរឲ្យយាយមានសុខភាពល្អ សំណាងល្អ និងមានសុភមង្គលក្នុងគ្រួសារយាយណា។

ខ៖ ចាស សាធុ សាធុ ឲ្យចៅឯងអាយុវែងណាចៅណា។

ក៖ បាទ។